ក

## មាតិកា

***

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៥-៩-១៩៩៣ | - ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០០/១៣៥ តែងតាំងជាកិច្ចបច្ឆាមរណៈ ចំពោះលោក ចៅ យុន ប្រយូទឡ្យ ប៉ាត់ ជាសម្តេច | ១៣១៧ |
| ០២-៨-២០០០ | - ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០០/១៥៣ ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក ង៉ាន ស៊ុនគ្វីងប៊ីន (NGAN SHUN KWING BEN ) សញ្ជាតិដើម កាណាដា | ១៣១៨ |
| ០២-៨-២០០០ | - ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០០/១៥៤ ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក យ៉ាន ស៊ើនជីង ( NYAN SUEN CHING ) សញ្ជាតិដើម អង់គ្លេស | ១៣១៩ |
| ០២-៨-២០០០ | ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០០/១៥៥ តែងតាំងឯកឧត្តម អ៊ុច វឌ្ឍឌ្ឍនា ជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ - ឯកឧត្តម ខូវ ម៉េងហ៊ាន់ ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១៣២០ |
| | -ឯកឧត្តម ខាយ យុនហេង ជារដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច | |


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ០៨-៨-២០០០ | - អនុក្រឹត្យ លេខ ៥០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៣២១ |
| ០១-៨-២០០០ | - អនុក្រឹត្យ លេខ ២៨៩ អនក្រ.តត ស្តីពីការដកហូតមុខតំណែងអ្នកគ្រប់គ្រងក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា | ១៣២២ |

| | | |
|---|---|---|
| ០១-៨-២០០០ | - អនុក្រឹត្យលេខ ២៩០ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចគ្រប់គ្រងក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា | ១៣២៣ |
| -៨-២០០០ | - អនុក្រឹត្យលេខ ២៩១ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ | ១៣២៤ |
| ០៣-៨-២០០០ | - អនុក្រឹត្យលេខ ២៩២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៣២៥ |
| ០៤-៨-២០០០ | - អនុក្រឹត្យលេខ ២៩៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣២៦ |
| ០៤-៨-២០០០ | - អនុក្រឹត្យលេខ ២៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣២៨ |
| ០៤-៨-២០០០ | - អនុក្រឹត្យលេខ ២៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣២៩ |
| ០៤-៨-២០០០ | - អនុក្រឹត្យលេខ ២៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៣០ |
| ០៤-៨-២០០០ | - អនុក្រឹត្យលេខ ២៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៣១ |
| ០៤-៨-២០០០ | - អនុក្រឹត្យលេខ ២៩៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ១៣៣២ |
| ០៤-៨-២០០០ | - អនុក្រឹត្យលេខ ២៩៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៣៣៣ |
| ០៤-៨-២០០០ | - អនុក្រឹត្យលេខ ៣០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៣៤ |
| ០៤-៨-២០០០ | - អនុក្រឹត្យលេខ ៣០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៣៥ |
| ០៤-៨-២០០០ | - អនុក្រឹត្យលេខ ៣០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៣៣៦ |


## ២-សេចក្តីសំរេច


| | | |
|---|---|---|
| ០១-៨-២០០០ | - សេចក្តីសំរេច លេខ ៥០ សសរ ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវបាតុភូត ដែលកើតមានឡើងចំពោះយន្តហោះ ជូនព្រះរាជដំណើរ | ១៣៣៧ |
| ០១-៨-២០០០ | - សេចក្តីសំរេចលេខ ៥១ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះកម្ពុជា -បែលហ្ស៊ិក | ១៣៣៨ |
| ០៨-៨-២០០០ | - សេចក្តីប្រកាស លេខ ០៣ ប្រក របស់រាជរដ្ឋាភិបាល ស្តីពីការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅកម្ពុជា | ១៣៤០ |

# គ

## III- ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

### ប្រកាស


| | | |
|---|---|---|
| ០៧-៨-២០០០ | - ប្រកាសលេខ ៩០០ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ "គ្រូចនេពនិម្មិត ហ៊ុន សែន" ទៅជាវិទ្យាល័យ " គ្រូចនេពនិម្មិត ហ៊ុន សែន" ស្ថិតនៅក្នុងសង្កាត់ទួលល្វា ខ័ណ្ឌ ប៉ៃលិន ក្រុងប៉ៃលិន | ១៣៩២ |
| ០៧-៨-២០០០ | - ប្រកាសលេខ ៩០១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ស្ពឺ ស្ថិតនៅក្នុងឃុំ ស្ពឺ (ក) ស្រុកបាភ្នំ ខេត្តព្រៃវែង | ១៣៩៤ |
| ០៧-៨-២០០០ | - ប្រកាសលេខ ៩០២ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " ចឹងកេងកង " ទៅជាវិទ្យាល័យ "ចឹងកេងកង" ស្ថិតនៅក្នុងសង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ | ១៣៩៥ |

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៧០០/១៣៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

តែងតាំង

ជាកិច្ចបច្ចាមរណៈ

ចំពោះ លោកចៅឃុន ប្រយូរវង្ស ប៉ាត់

ជា

សម្តេច

ធ្វើនៅព្រះបរមរាជវាំង ភ្នំពេញ,ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

ព្រះហស្តលេខា

នរោត្តម សីហនុ

***

## ព្រះរាជក្រឹត្យ នស/រកត/០៨០០/១៤៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែ សីហា ឆ្នាំ ២០០០

### ត្រាស់បង្គាប់

មាត្រា ១ .-ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ង៉ាន ស៊ុនគ្វីនប៊ីន (NGAN SHUN KWING BEN) សញ្ជាតិដើម កាណាដា កើតថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ ១៩៥២ នៅ ហ្វូជីន ប្រទេសចិន ។

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

# ព្រះរាជក្រឹត្យ នស/រកត/០៨០០/១៨៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែ សីហា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

**មាត្រា ១ .-** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យ៉ាន ស៊ានជីង** (YAN SUEN CHING) សញ្ជាតិ ដើម អង់គ្លេស កើតថ្ងៃទី២១ ខែ តុលា ឆ្នាំ ១៩៥៥ នៅ ហ្វៀគៀន ប្រទេសចិន ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០០**

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

***

# ព្រះរាជក្រឹត្យ នស/រកត/០៨០០/១៩៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់លិខិតលេខ ៦៤២ រស ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ ២០០០ ស្តីពីលទ្ធផលនៃការបោះឆ្នោតសំដែងការទុកចិត្តរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៤ ខែ សីហា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំង :

-ឯកឧត្តម អ៊ុក វណ្ណវឌ្ឍនា ជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជំនួសលោកជំទាវ លី វួចឡេង ដែលត្រូវបានតែងតាំងជាប្រធានសាលាឧទ្ធរណ៍ ។

-ឯកឧត្តម ខួច ម៉េងហ៊ាន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជំនួសឯកឧត្តម ចាន់ ស៊ីណា ដែលត្រូវបានតែងតាំងជាប្រតិភូនៃរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរងរាជធានីភ្នំពេញ ។

-ឯកឧត្តម ខាយ ឃុនហេង ជារដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ជំនួសឯកឧត្តម ខួច ម៉េងហ៊ាន ។

-ឯកឧត្តម អ៊ិន ទិសាអ៊ុម ជារដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ជំនួសឯកឧត្តម ស្រី វណ្ណផ្ទង់ ដែលបានទទួលមរណភាព ។

មាត្រា ២ .- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៥០ អនក្រ.បក

### ស្ដីពី ការផ្ទេរឥណទានថវិកា

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមនស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ .- ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន៤០០លានរៀល (បួនរយលានរៀល) ពីជំពូក ៩១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) របស់ក្រសួងផែនការ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០០ ។

មាត្រា ២ .- ឥណទានថវិកា ក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់ចំណាយដំណើរការរៀបចំកម្មវិធីជាតិ ដើម្បីអភិវឌ្ឍន៍កម្ពុជា ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

# អនុក្រឹត្យ លេខ ២៨៩ អនក្រ.តត

# ស្តីពី

# ការដកហូតពីមុខតំណែងអ្នកគ្រប់គ្រង ក្រុមហ៊ុនអាកាសចរណ៍តូមិនកម្ពុជា

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

មាត្រា ១ .- ត្រូវបានដកចេញពីមុខតំណែងអ្នកគ្រប់គ្រងក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

១-លោក **ជុំន់ ចន្ថា** ពីប្រធានក្រុមហ៊ុននិងប្រធានប្រតិបត្តិ នៃក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា ។

២-លោក **ឆេត ហៃន** ពីអនុប្រធាន ក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា ។

មាត្រា ២ .- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្រុមហ៊ុនអាការចរណ៍ភូមិន្ទកម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ២៩០ អនក្រ.តត

## ស្តីពី ការប្រគល់ភារកិច្ច

## គ្រប់គ្រងក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អោយទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា ជាបណ្តោះអាសន្ន ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងឯកឧត្តម សុខ អាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ២៩១ អនក្រ.តត
## ស្តីពី ការផ្ទេរភារកិច្ច
## និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

មាត្រា ១ .- ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងជូននាយនគរបាលជាតិជាន់ខ្ពស់ ដូចមានរាយនាមខាងក្រោម ៖

ក/-ផ្ទេរភារកិច្ច :

១-ឧត្តមសេនីយ៍ត្រី ម្រឹក សារឿន ពីប្រធាននាយកដ្ឋានជនបរទេសទៅជាសមាជិកក្រុមអ្នកច្បាប់ ច្បាប់របស់ក្រសួងមហាផ្ទៃមានឋានៈស្មើប្រធាននាយកដ្ឋាន។

២-ឧត្តមសេនីយ៍ត្រី យុន ឈុនី ពីអនុប្រធានទី១ នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់ សាធារណៈ ទៅជាប្រធាននាយកដ្ឋានជនបរទេស នៃក្រសួងមហាផ្ទៃ ។

៣-ឧត្តមសេនីយ៍ត្រី ហេង ហាក់ ពីនាយករងខុទ្ទកាល័យក្រសួង មហាផ្ទៃ ទៅជាអនុប្រធានទី១ នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃក្រសួង មហាផ្ទៃ ។

៤-ឧត្តមសេនីយ៍ត្រី ថោង លឹម ពីប្រធានមន្ទីរប្រដាប់គ្រឿងញៀនទៅជា អនុប្រធាននាយកដ្ឋាន កណ្តាលនគរបាលព្រំដែន នៃក្រសួងមហាផ្ទៃ ។

ខ/-តែងតាំងស្នងតំណែង :

-វរសេនីយ៍ឯក ពេជ្រ ជីវ័ន្ត ពីអនុប្រធានមន្ទីរ ទៅជាប្រធានមន្ទីរប្រដាប់គ្រឿងញៀន នៃ ក្រសួងមហាផ្ទៃ ។

មាត្រា ២ .- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ២៩២ អនក្រ.តត

## ស្តីពី ការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន

-យោងតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

**សំរេច**

មាត្រា ១ .-ត្រូវបានតែងតាំងលោកស្រី ឌឹម សុគន្ធារ ជានាយក នៃនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ២ .- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

**អនុក្រឹត្យ លេខ ២៩៣ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា ១ .**-ត្រូវបានប្រគល់ មេដាយស្ហាមនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និងជូនព្រះគ្រូចៅអធិការ និងគណៈកម្មការអាចារ្យវត្តជើងភ្នំមង្គលា ឃុំបរកោស្សារ ស្រុកដូនកែវ ខេត្តតាកែវ ដែលបានបរិច្ចាគធនធាន និងស្វែងរកបច្ច័យសាងសង់សមិទ្ធផលផ្សេងៗ ក្នុងវត្តជើងភ្នំមង្គលា ដូចជាព្រះវិហារ កុដិ សាលាឆាន់ សាលារៀន ផ្លូវលំ ។ល។ ចំណាយអស់ថវិកាសរុបចំនួន ១៥៣.៤២២ ដុល្លារអាមេរិក និង ២០៨.៩៧៧.៦០០រៀល ដូចមានព្រះនាម និងនាមខាងក្រោមនេះ :

**ក-មេដាយមាសស្ហាមនាជាតិ :**

-ព្រះតេជគុណ **នឹម សុវណ្ណា** ព្រះគ្រូចៅអធិការវត្ត

**ខ-មេដាយប្រាក់ស្ហាមនាជាតិ :**

១-លោកតា **មុំ គឹម**

២-លោកតា **សេខ សុខ**

**គ-មេដាយសំរិទ្ធស្ហាមនាជាតិ :**

១-លោកតា **ជៀម តោម**

២-លោកតា **សំ ឈន**

**មាត្រា ២ .**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

អនុក្រឹត្យ លេខ ២៩៤ អនក្រ.តត

ស្តីពី

ការជូនមេដាយស្ថាបនាជាតិ

***

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សំរេច

មាត្រា ១ .-ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ប្រគេនព្រះតេជគុណ KYOUSHIN SATAKE គង់នៅវត្ត SHONENJI TEMPLE (Japan) ដែលបានធ្វើអំណោយអាគារសិក្សាមួយខ្នង មាន០៥បន្ទប់ រួមទាំងសម្ភារៈសិក្សា និងបង្គន់អនាម័យផង ជូនសាលាបឋមសិក្សាអង្គធំ ក្នុងឃុំត្នោត ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចំណាយអស់ទឹកប្រាក់ចំនួន ១៩.៩៥៥ដុល្លារអាមេរិក ។

មាត្រា ២ .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

# អនុក្រឹត្យ លេខ ២៩៥ អនក្រ.តត
## ស្តីពី
## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រគល់សប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** .-ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនកញ្ញា អាយកូ នីស៊ី (KAIKO NISHI ) សប្បុរសជន ជនជាតិជប៉ុន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជាថវិកាចំនួន ៣១.៥០៥ ដុល្លារអាមេរិក ក្នុងការកសាងនា អាគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ និងអាគារទីចាត់ការសាលារៀន ០១ខ្នង មាន ០២បន្ទប់ នៅក្នុងបរិវេណសាលាបឋមសិក្សា ព្រះផុស ឃុំព្រះផុស ស្រុកគាស់ក្រឡ (ស្រុកថ្មី) ខេត្តបាត់ដំបង ។

**មាត្រា ២** .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ២៩៦ អនក្រ.តត
## ស្តីពី
## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

## សំរេច

មាត្រា ១ .-ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ ប្រគេន និងជូនសប្បុរសជន ដែលបានបរិច្ចាគធនធានជួយកសាង សមិទ្ធផលផ្សេងៗ ក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ ៖

ក-មេដាយមាស ស្ថាបនាជាតិ ៖

-ព្រះតេជគុណ យី សុផារិទ្ធ ទឹកប្រាក់ ១០.០០០ USD

ខ-មេដាយសំរិទ្ធ ស្ថាបនាជាតិ ៖

១-លោក ហៃ លីអៀង ទឹកប្រាក់ ៣.០០០ USD

២-លោក ធុច ថាត ទឹកប្រាក់ ១.៥០០ USD

៣-លោក ឯម ថន ទឹកប្រាក់ ១.៥០០ USD

៤-លោក ឈឹម សំ ទឹកប្រាក់ ១.៥០០ USD

៥-លោកស្រី វង់ ស៊ុយហ៊ីង ទឹកប្រាក់ ១.៥០០ USD

៦-លោកស្រី ជ្រួន គីមអៀន ទឹកប្រាក់ ១.៥០០ USD

៧-លោកស្រី ជ្រួន គីមអ៊ីវ ទឹកប្រាក់ ១.៥០០ USD

៨-លោកស្រី ជ្រា គីមលាង ទឹកប្រាក់ ១.៥០០ USD

៩-លោក ជា សីហា ទឹកប្រាក់ ១.៥០០ USD

១០-លោក ទង់ ហាក់ថៃ្ង ទឹកប្រាក់ ១.៥០០ USD

មាត្រា ២ .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ២៩៧ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សំរេច

មាត្រា ១ .-ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនឯកឧត្តមឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយសាងសង់អាគារសិក្សាមួយខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់សម្ភារឹមសិក្សាគ្រប់គ្រាន់ផង នៅក្នុងបរិវេណសាលាបឋមសិក្សាពោធិទន្ទឹម ឃុំស្វាយ រំពា ស្រុកស្វាយទាប ខេត្តស្វាយរៀង ចំណាយអស់ទឹកប្រាក់ចំនួន ២៥.៨៧៥ ដុល្លារអាមេរិក ។

មាត្រា ២ .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ២៩៨ អនក្រ.តត

## ស្តីពី ការជូនមេដាយ សហមេត្រី

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

មាត្រា ១ .-ត្រូវបានប្រគល់ មេដាយ សេនាសហមេត្រី ជូនលោក កែន ណូដាវិស (KEN NOAH DVIES) នាយរង អង្គការកម្មវិធីស្បៀងអាហារពិភពលោក ដែលមានស្នាដៃល្អក្នុងការបំពេញកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាដៃគូរ លើគំរោងអភិវឌ្ឍន៍ជនបទ ។

មាត្រា ២ .-ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

# អនុក្រឹត្យ លេខ ២៩៩ អនក្រ.តត
## ស្តីពី
## ការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា ១ .**-ត្រូវបានប្រគល់ **មេដាយ ប្រាក់ការងារ** ជូនមន្ត្រីបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានស្នាដៃល្អ ក្នុងការបំរើការងារ ផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចមានរាយនាមខាងក្រោមនេះ :

១-លោក គង់ គាំ អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តស្វាយរៀង និងជាប្រធានគ្រប់គ្រងគំរោងផ្លូវលំ នៃកម្មវិធីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី

១-លោក ម៉ាក់ ទើង អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ និងជាប្រធានគ្រប់គ្រងគំរោងផ្លូវលំ នៃកម្មវិធីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី

**មាត្រា ២ .**- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ៣០០ អនក្រ.តត
## ស្តីពី
## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សមាគម ឥស្លាមកម្ពុជា

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០៣រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ក្នុងការជួយកសាងអាគារសិក្សា នៅក្នុងខេត្តកំពង់ចាម និងខេត្តតាកែវ ដូចមានរាយនាមនិងចំនួនទឹកប្រាក់អំណោយខាងក្រោមនេះ :

| | |
|---|---|
| ១-លោក ហ៊ីគ្រី តួនមូហាំម៉ាត់ | ជួយសាងសង់អាគារសិក្សា ០១ខ្នងមាន០៥បន្ទប់ នៅភូមិបឹងព្រួល ឃុំបឹងព្រួល ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ចំនួន ១៧.០០០ ដុល្លារអាមេរិក |
| ២-លោក សេន និត | ជួយសាងសង់អាគារសិក្សា ០១ខ្នងមាន០៥បន្ទប់ នៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ចំនួន ២៣.០០០ ដុល្លារអាមេរិក |
| ៣-លោក សាន់ សាលីម | ជួយសាងសង់អាគារសិក្សា ០១ខ្នងមាន០៦បន្ទប់ នៅភូមិកំពង់យោង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ចំនួន ២៨.០០០ ដុល្លារអាមេរិក |

មាត្រា២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អភិបាលខេត្តកំពង់ចាម អភិបាលខេត្តតាកែវ និងសមាគមផ្សាមកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ៣០១ អនក្រ.គត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

មាត្រា ១ .-ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនម្ចាស់អំណោយដែលបានផ្តល់ថវិកា សំរាប់កសាងអាគារសិក្សាថ្មី ចំនួន១៤ខ្នង មាន៤៧បន្ទប់ ជួសជុលមួយខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់សម្ភារៈសិក្សាផ្សេងៗផង នៅក្នុងមូលដ្ឋានស្រុកអង្គរបូរី ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់សរុបចំនួន ១៥៥.២១០,៣០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ :

១-ស្ថានឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា

២-ក់រោង RD និង RP

មាត្រា២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ៣០២ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់គណៈអភិបាលខេត្តមណ្ឌលតាកែវ

## សំរេច

មាត្រា ១ .-ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ដែលបានបរិច្ចាគបច្ច័យ និងធនធានជួយកសាងសមិទ្ធផលផ្សេងៗនៅក្នុងបរិវេណ "សោភណារាម" ឃុំពោធិវិចាក និងក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវទាំងមូល ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :

ក-មេដាយមាស ស្ថាបនាជាតិ :

១-ព្រះតេជគុណ ត ឌុក ព្រះចៅអធិការវត្តសោភណារាម បច្ច័យចំនួន ១២.១០៧ USD

២-ព្រះតេជគុណ ស ឆុច ព្រះចៅអធិការវត្តស្ទឹងមានជ័យ បច្ច័យចំនួន ១២.៨៤៧ USD

៣-ឯកឧត្តម ហេង មុំ អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ទឹកប្រាក់ចំនួន ១៥.២៥០ USD

ខ-មេដាយប្រាក់ ស្ថាបនាជាតិ :

១-លោក ផាត់ សុខ សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ៥.២០០USD

មាត្រា២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៥០ សសរ

### ស្តីពី

### ការបង្កើតគណៈកម្មការស្រាវជ្រាវបាតុភាព ដែលកើតមានឡើងចំពោះយន្តហោះជូនព្រះរាជដំណើរ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសភាពការណ៍ចាំបាច់ចំពោះមុខ

### សំរេច

ប្រការ ១ : បង្កើតគណៈកម្មការស្រាវជ្រាវបាតុភាពដែលកើតមានឡើងចំពោះយន្តហោះលេខ 9MMCធុនC737-400 ដែលត្រូវជូនព្រះរាជដំណើរនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០ វេលាម៉ោង ៨.០០នាទីព្រឹក ដែលមានសមាសភាពដូចខាងក្រោមនេះ :

| | | |
|---|---|---|
| ១-ឯកឧត្តម ហុក ឡុងឌី | អគ្គនាយកនគរបាលជាតិ | ជា ប្រធាន |
| ២-ឯកឧត្តម មល់ រឿប | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | ជា សមាជិក |

៣-ឯកឧត្តម សៅ សុខា មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជា សមាជិក

៤-ឯកឧត្តម នេត សាវឿន ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ជា សមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

-ស្រាវជ្រាវគ្រប់មូលហេតុអោយបានល្អិតល្អន់ ចំពោះបាតុភាពដែលកើតមានឡើងចំពោះយន្តហោះ ដែល ត្រូវជូនព្រះរាជដំណើរ នៅព្រឹកថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០ នេះ

-មានសិទ្ធិកោះអញ្ជើញគ្រប់សមាសភាពពាក់ព័ន្ធមកបំភ្លឺ

-រាយការណ៍ពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល

-មានសិទ្ធិប្រើប្រាស់គ្រោះរបស់ក្រសួងមហាផ្ទៃ

-អនុប្រធាន និងសមាជិកទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ៥១ សសរ

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះ កម្ពុជា-បែលហ្ស៊ិក

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះ កម្ពុជា-បែលហ្ស៊ិក ដែលមានសមាសភាពដូចខាងក្រោមនេះ :

| | | |
|---|---|---|
| ១-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | | ប្រធាន |
| ២-ឯកឧត្តម អ៊ុំ គឹមអន | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម ខុង សំនួន | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| -តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| -តំណាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | សមាជិក |
| -តំណាង ក្រសួងអប់រំ យុវជន និងកីឡា | | សមាជិក |
| -តំណាង ក្រសួងអភិវឌ្ឍន៍ជនបទ | | សមាជិក |
| -តំណាង ក្រសួងសុខាភិបាល | | សមាជិក |
| -តំណាង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| -តំណាង ក្រសួងសាធារណការនិងដឹកជញ្ជូន | | សមាជិក |
| -តំណាង ក្រសួងការពារជាតិ | | សមាជិក |
| -តំណាង ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ | | សមាជិក |
| -ប្រធាននាយកដ្ឋានអឺរ៉ុប នៃក្រសួងការបរទេស | | សមាជិក |
| | | ទទួលបន្ទុកលេខាធិការ |

ប្រការ ២ : គណៈកម្មការចំរុះនេះមានបេសកកម្ម :

-ពិចារណាបញ្ហាដែលកើតមានឡើង ក្នុងក្របខណ្ឌនៃការអនុវត្តកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលបែលហ្ស៊ិក និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការ លើវិស័យអប់រំ សុខាភិបាល អភិវឌ្ឍន៍ ជនបទ គមនាគមន៍ ការ[illegible] និងការកាត់បន្ថយអាវុធធុនស្រាល ។

ប្រការ ៣ : ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការនេះមានភារកិច្ច និងសិទ្ធិ :

-បង្កើតប្រតិទិនប្រចាំឆ្នាំមួយ សំរាប់អនុវត្តគំរោងផែនការ ដែលភាគីទាំងពីរបានឯកភាព ។

-ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីស្នើសុំគោលការណ៍ ឬមតិណែនាំ ។

-សមាជិកនៃគណៈកម្មការ ត្រូវចូលរួមប្រជុំការងារ តាមការអញ្ជើញរបស់ប្រធាន ។

-មានសិទ្ធិប្រើត្រា របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តន៍ភារកិច្ចពាក់ព័ន្ធចាំបាច់ ។

ប្រការ ៤ : ក្រសួងស្ថាប័ននីមួយៗ ត្រូវបញ្ជូនឈ្មោះនិងមុខងារនៃតំណាងរបស់ខ្លួន ដូចមានចែងក្នុងប្រការ១ មកប្រធានគណៈកម្មការចំរុះនេះ ដើម្បីងាយស្រួលក្នុងការបំពេញភារកិច្ចរបស់គណៈកម្មការ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អគ្គលេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍ជនបទកម្ពុជា ប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## ៣- សេចក្តីប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០០

### សេចក្តីប្រកាស

### សេចក្តីប្រកាស លេខ ០៣ ប្រក

### របស់រាជរដ្ឋាភិបាល

### ស្តីពីការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅកម្ពុជា

* * *

កៅស៊ូធម្មជាតិ គឺជាដំណាំកសិ-ឧស្សាហកម្ម ដែលបានផ្តល់ផលប្រយោជន៍យ៉ាងសំខាន់ សំរាប់សេដ្ឋកិច្ចជាតិ ។ ជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាបានស្រូបយករូបិយប័ណ្ណយ៉ាងច្រើនដែលបានមកពីការនាំចេញផលិតផលកៅស៊ូធម្មជាតិ ។

ប្រទេសកម្ពុជាមានដីក្រហម និងដីប្រភេទផ្សេងៗទៀតរាប់សែនហិកតាដែលមានសក្តានុពលអាចដាំដុះកៅស៊ូបាន ប៉ុន្តែរហូតមកទល់បច្ចុប្បន្ននេះ យើងនៅពុំទាន់បានប្រើប្រាស់អោយអស់សក្តានុពលនេះនៅឡើយ ។

ការដាំដុះកៅស៊ូឡើងវិញស្ថិតនៅក្នុងស្ថានភាពមួយយឺតយ៉ាវ និងមិនទាន់សមស្របតាមសភាពការណ៍ នៃការអភិវឌ្ឍន៍ដំណាំកៅស៊ូនៅទូទាំងប្រទេសនៅឡើយ ។

ទោះបីជាតែក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ និន្នាការនៃតម្លៃកៅស៊ូធម្មជាតិនៅលើទីផ្សារអន្តរជាតិ បានធ្លាក់ចុះយ៉ាងខ្លាំង ដែលមិនធ្លាប់មានសោះតាំងពីមុនមក តែតម្លៃកៅស៊ូនឹងងើបឡើងវិញនៅក្នុងអនាគតដ៏ខ្លីខាងមុខ ហើយដំណាំកៅស៊ូនៅតែរក្សាបាននូវនាទីមួយចំណែកយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចជាតិ ។

ដើម្បីអោយដំណាំកៅស៊ូមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សលើគ្រប់ផ្នែក ទាំងផ្នែកកសិ-ឧស្សាហកម្ម ទាំងផ្នែកឯកជន និងជាពិសេសផ្នែកដំណាំកៅស៊ូគ្រួសារ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផ្តល់អាទិភាពខ្ពស់ដល់ដំណាំនេះ ដោយបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក្នុងអាណត្តិទី២ ថា "<u>រាជរដ្ឋាភិបាលនឹងលើកទឹកចិត្តដល់កសិករ អោយដាំដំណាំកៅស៊ូនៅលើចំការតូចតាចរបស់ខ្លួន តាមគោលនយោបាយ នៃការផ្តល់ឥណទាន ការផ្តល់សិទ្ធិលើការកាន់កាប់ និងការប្រើប្រាស់ដីធ្លីអោយបានសមស្រប</u>" ។

គោលបំណងដ៏សំខាន់របស់រាជរដ្ឋាភិបាល ក្នុងការជំរុញការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ គឺសំដៅ :

* អភិវឌ្ឍន៍ដំណាំកៅស៊ូនៅកម្ពុជាអោយបានរីកចំរើនឆាប់រហ័ស ។
* ជួយបង្កើនប្រាក់ចំណូល ដែលបានមកពីការធ្វើអាជីវកម្មកៅស៊ូដល់កសិករ និងជួយកាត់បន្ថយភាពក្រីក្រនៅតាមជនបទ ។
* បង្កើនប្រភពប្រាក់ចំណូលដល់ខឿនសេដ្ឋកិច្ចជាតិ តាមរយៈការនាំចេញផលិតផលកៅស៊ូ ។
* ជួយការពារបរិស្ថានទល់នឹងភាពហួតហែងក្តៅខ្លាំងនៃធម្មជាតិ និងការហូរច្រោះដី ។

គោលនយោបាយអភិវឌ្ឍន៍នេះ គឺសំដៅជួយកសិករតូចតាចអោយដាំដំណាំកៅស៊ូដែលមានទិន្នផលខ្ពស់ រួមទាំងដំណាំកសិផលផ្សេងៗទៀតនៅតាមចន្លោះរងកៅស៊ូ សំរាប់ធានាជីវភាពរស់នៅរបស់កសិផល របួតដល់រយៈពេលនៃការចាប់ផ្តើមចៀរជ័រកៅស៊ូ ។

កសិករដែលស្ម័គ្រចិត្តចូលរួមក្នុងគំរោងអភិវឌ្ឍន៍នេះ ត្រូវបានរាជរដ្ឋាភិបាលធានា និងលើកទឹកចិត្ត ដោយ :

- ផ្តល់ជូននូវសិទ្ធិក្នុងការកាន់កាប់ ការប្រើប្រាស់ដីចំការ ការបន្តមរតក ឬការផ្ទេរសិទ្ធិអោយអ្នកដទៃ ព្រមទាំងរដ្ឋធានាមិនធ្វើជាតូបនីយកម្មឡើយ ។
- សំរួលដល់ការខ្ចីឥណទានតាមរយៈធនាគារអភិវឌ្ឍន៍ជនបទតាមលក្ខខណ្ឌ និងវិធីសាស្ត្រនានាដែលមាន

• ផ្តល់ជូននូវការបណ្តុះបណ្តាល និងសេវាបច្ចេកទេសក្នុងការដាំដុះ ការថែទាំ រហូតដល់ការប្រមូលផល ព្រមទាំងផ្តល់ព័ត៌មាន ស្តីពីទីផ្សារផលិតផលកៅស៊ូ ។

• ផ្តល់នូវសិទ្ធិក្នុងការទទួលផលពីចំការរបស់ខ្លួន ការកែច្នៃ និងការលក់ដូរផលិតផលកៅស៊ូដោយសេរី ។

• កសិករមានសិទ្ធិរៀបចំសមាគមកសិករដាំកៅស៊ូ សំរាប់ការពារផលប្រយោជន៍របស់សមាជិកម្នាក់ៗ ។

រាជរដ្ឋាភិបាលសង្ឃឹមថា ប្រជាកសិករនៅទូទាំងប្រទេសនឹងចូលរួមយ៉ាងសកម្មនៅក្នុងការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារ សំរាប់លើកស្ទួយសេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ខ្លួនប្រកបដោយសុភមង្គល ។

ទទួលបានសេចក្តីប្រកាសនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មការតាមដាន និង ជំរុញការអនុវត្តនីតិរោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយអោយបានទូលំទូលាយ និងខិតខំអនុវត្តការងារនេះ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងរាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលការងារដែលសំរេចបាន និងបញ្ហានានាដែលកើតឡើង ដើម្បីមានវិធានការណ៍ជាក់ស្តែង ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## III– ការងារបណ្តាក្រសួង

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០

**ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

**ប្រកាស**

**ប្រកាស លេខ ៩០០ អយក.ប្រក**

**ស្តីពីការពង្រីក អនុវិទ្យាល័យ "ក្រូចនេពនិវិត្ត ហ៊ុន សែន"**

**ទៅជាវិទ្យាល័យ "ក្រូចនេពនិវិត្ត ហ៊ុន សែន" ស្ថិតនៅក្នុងសង្កាត់**

**ក្នុងភូមិ ខណ្ឌ ប៉ៃលិន ក្រុង ប៉ៃលិន ។**

* * *

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំ ចំនេះទូទៅ ១២ឆ្នាំ ។

-បានឃើញអនុក្រឹត្យលេខ ២១/អនក្រ-បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១-កំរិត២ ។

-យោងលិខិតស្នើសុំរបស់ប្រធានមន្ទីរ អប់រំ យុវជន និងកីឡា ក្រុងប៉ៃលិន លេខ ៤៣៤-៩៩ អយក.កបល ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដោយមានយោបល់ឯកភាពពីប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុករាជរដ្ឋាភិបាលក្រុងប៉ៃលិន

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

## សំរេច

ប្រការ ១ : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ " គ្រួនចេតនិម្មិត ហ៊ុន សែន " បច្ចុប្បន្នទៅជា វិទ្យាល័យ "គ្រួនចេត និម្មិត ហ៊ុន សែន " ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាក្រុងប៉ៃលិន និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

អ៊ឹម សិទ្ធី

***

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០

**ប្រកាស លេខ ៩០១ អយក.ប្រក**

**ស្តីពីការបើក អនុវិទ្យាល័យ ស្តី ស្ថិតនៅក្នុង ឃុំ ស្តី (ក)**

**ស្រុក បាភ្នំ ខេត្តព្រៃវែង**

* * *

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។

-បានឃើញអនុក្រឹត្យលេខ ២១អនក្រ-បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១-កំរិត២ ។

-យោងលិខិតស្នើសុំរបស់ សហគមន៍ ឃុំស្តី(ក) ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តព្រៃវែង ។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យ ដែលមានឈ្មោះថា : អនុវិទ្យាល័យ " ស្តី " ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង និងនាយកអនុវិទ្យាល័យសោភី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

អ៊ឹម សិទ្ធី

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០

ប្រកាស លេខ ៩០២ អយក.ប្រក

ស្តីពីការពង្រីក អនុវិទ្យាល័យ <បឹងកេងកង> ទៅជា វិទ្យាល័យ <បឹងកេងកង>

ស្ថិតនៅក្នុងសង្កាត់ បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

* * *

## រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។

-បានឃើញអនុក្រឹត្យលេខ ២១អនក្រ-បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១-កំរិត២ ។

-យោងលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជននិងកីឡា រាជធានីភ្នំពេញ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ដោយមានយោបល់ឯកភាពពីប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

-តាមសេចក្ដីស្នើសុំរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ <មីងកេងកង> បច្ចុប្បន្នទៅជា វិទ្យាល័យ <មីងកេងកង> ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងនាយកវិទ្យាល័យសាមី ត្រូវអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**រដ្ឋលេខាធិការ**

ហត្ថលេខានិងត្រា

**អ៊ឹម សិទ្ធី**

***